**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧១៥ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការបង្កើតវិទ្យាស្ថានកីឡា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

# សម្រេច

**មាត្រា១ ._**

ត្រូវបានបង្កើតគ្រឹះស្ថានឧត្តមសិក្សាសាធារណៈមួយដែលមានឈ្មោះថា វិទ្យាស្ថានស្លឹករឹត SLEUK RITH INSTITUTE សរសេរជាអក្សរកាត់ជាភាសាខ្មែរ វ.ស.រ. និងជាភាសាអង់គ្លេស S.R.I.។

**មាត្រា២ ._**

វិទ្យាស្ថានស្លឹករឹត មានទីតាំងស្ថិតនៅក្នុងបរិវេណវិទ្យាល័យបឹងត្របែក មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ វិទ្យាស្ថាននេះស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ទៅអនាគត វិទ្យាស្ថាននេះអាចសុំប្តូរឈ្មោះថ្មីឬទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៣ ._**

វិទ្យាស្ថានស្លឹករឹតមានផ្នែកសំខាន់ៗដូចខាងក្រោម៖

- សារមន្ទីរ
- មជ្ឈមណ្ឌលស្រាវជ្រាវ
- មជ្ឈមណ្ឌលបណ្តុះបណ្តាលនិងស្រាវជ្រាវលើមុខជំនាញឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ វិវាទកម្ម និងសិទ្ធិមនុស្ស ដោយធ្វើការបណ្តុះបណ្តាលគ្រប់កម្រិតឧត្តមសិក្សាលើមុខជំនាញទាំងនេះ
- មជ្ឈមណ្ឌលសារព័ត៌មាន។

**មាត្រា៤ ._**

វិទ្យាស្ថានស្លឹករឹត ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍន៍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។

**មាត្រា៥ ._**

នាយកវិទ្យាស្ថានស្លឹករឹតមានភារកិច្ច៖

- អនុវត្តតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំផ្ទៃក្នុងនៅឧត្តមសិក្សា
- រៀបចំតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងវិទ្យាស្ថាន និងវិធានផ្ទៃក្នុងសម្រាប់ការគ្រប់គ្រងការសិក្សាឱ្យបានច្បាស់លាស់
- ត្រូវរៀបចំកម្មវិធីសិក្សាលម្អិតតាមមុខជំនាញ ដើម្បីស្នើសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា មុននឹងចាប់ដំណើរការបណ្តុះបណ្តាល
- ធ្វើរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំមកអគ្គនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា
- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងវិទ្យាស្ថានស្លឹករឹត។

**មាត្រា៦ ._**

និស្សិតឬអ្នកស្រាវជ្រាវជាតិនិងអន្តរជាតិ ដែលបានរៀនចប់តាមកម្មវិធីសិក្សា និងស្រាវជ្រ ហើយទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រឬវិញ្ញាបនបត្រ តាម មុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះផ្តល់ឱ្យដោយវិទ្យាស្ថានស្លឹករឹត ក្នុងករណីវិទ្យាស្ថាន ស្លឹករឹតបំពេញនិងអនុវត្តបានតាមគោលការណ៍និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៧ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួល បន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ